# សន្លឹកព័ត៌មានសាធារណៈ

Ottawa County Health Department

## កាំពីឡូបាក់ទ័រ [CAMPYLOBACTER]

**តើ មេរោគ កាំពីឡូបាក់ទ័រ ជាអ្វី?**
កាំពីឡូបាក់ទ័រ គឺជាបាក់តេរីមួយដែលអាចធ្វើឱ្យមានរោគសញ្ញាទាក់ទងនឹងពោះ។

**តើកាំពីឡូបាក់ទ័រឆ្លងតាមរបៀបអ្វីខ្លះ?**
មេរោគកាំពីឡូបាក់ទ័រអាចឆ្លងតាមរបៀបខាងក្រោម:

- ការបរិភោគ ឬប៉ះពាល់សាច់មាន់ ឬសត្វស្លាបផ្សេង ដ៏ឆៅ ឬស្ទើរឆ្អិន។
- ការបរិភោគផ្លែឈើ បន្លែស្រស់ ឬទឹកដោះគោឆៅ ដ៏មានមេរោគ។
- ជួនកាលវាអាចឆ្លងតាមរយៈការប៉ះពាល់មនុស្ស ឬសត្វ ដែលមានមេរោគនេះ។

**តើអាចមានរោគសញ្ញាអ្វីខ្លះ?**
ធម្មតា រោគសញ្ញាចាប់ផ្តើម 2-5 ថ្ងៃក្រោយពីការឆ្លង មានអស់រយៈពេលប្រហែលមួយអាទិត្យ ហើយអាចមានរួមទាំង:

- ចង់ក្អួត
- ក្អួត
- រាគអាចម៍ (អាចមានឈាម)
- ចុករមួលពោះ
- ឈឺក្រពះ
- ក្តៅខ្លួន

**តើកាំពីឡូបាក់ទ័រត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?**
ដោយការពិសោធក្នុងមន្ទីរពិសោធ (លាមក)។

**តើវាត្រូវបានព្យាបាលយ៉ាងដូចម្តេច?**
មនុស្សភាគច្រើនជា ដោយមិនបាច់ព្យាបាលទេ។ ក្នុងករណីរាគអាចម៍ធ្ងន់ វេជ្ជបណ្ឌិតអាចបញ្ជាឱ្យផឹកថ្នាំអង់ទីប៊ីយ៉ូទិក។ ការផឹកទឹកច្រើន រួមទាំងទឹកអ៊ីឡិកត្រូលៃត៍ ដូចជា ក្តេតូរ៉េដ [Gatorade] អាចជួយបង្ការកង្វះជាតិទឹកក្នុងខ្លួនបាន។

**តើខ្ញុំអាចបង្ការការឆ្លង កាំពីឡូបាក់ទ័រ បានយ៉ាងដូចម្តេច?**

- ចំអិនសាច់សត្វស្លាបទាំងអស់ (ដូចជាសាច់មាន និងសាច់មាន់បារាំង) ឱ្យបានឆ្អិនទាំងស្រុង។
- កុំបរិភោគសាច់សត្វស្លាបដ៏ស្ទើរឆ្អិន។
- លាងដៃដោយសាប៊ូ មុន នឹងក្រោយពីប៉ះពាល់សាច់ឆៅ។
- ចៀសវាងទឹកដោះគោឆៅ និងទឹកមិនបរិសុទ្ធ។
- បញ្ជាក់ថា អ្នកដែលមានជម្ងឺរាគអាចម៍ ជាពិសេសកូនក្មេង លាងដៃឱ្យបានប្រយ័ត្ន ដោយសាប៊ូ និងទឹក។
- លាងដៃដោយសាប៊ូ និងទឹក ក្រោយពីប៉ះពាល់អាចម៍សត្វ។

**សម្រាប់ព័ត៌មានបន្ថែមទៀតអំពីការឆ្លងមេរោគកាំពីឡូបាក់ទ័រ:**

Ottawa County Health Department
www.miOttawa.org
Medline Plus/National Institutes of Health
www.nlm.nih.gov/medlineplus/ency/article/000224.htm

12251 James St., Suite 400
Holland, MI 49424
ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643
វ៉ិបសាយ: www.miOttawa.org